# លិខិតចំហរួម

# ស្តីពី

# ខួបគម្រប់ ១០ឆ្នាំ នៃការបាញ់សម្លាប់លោក ឈុត វុទ្ធី សកម្មជនការពារព្រៃឈើ និងធនធានធម្មជាតដ៏ល្បីឈ្មោះក្នុងប្រទេសកម្ពុជា

គិតមកដល់ត្រឹមថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ នេះ គឺមានរយៈពេល១០ឆ្នាំគត់ ដែលលោកឈុត វុទ្ធី ត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់នៅក្នុងទឹកដីខេត្តកោះកុង កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ។ លោក ឈុត វុទ្ធី ជាប្រធានអង្គការក្រុមអ្នកការពារធនធានធម្មជាតិ ដែលបានធ្វើការងារទៅលើការបណ្តុះបណ្តាល អប់រំ និងពង្រឹងសមត្ថភាពដល់សហគមន៍មូលដ្ឋានឱ្យបានយល់ដឹង ព្រមទាំងអនុវត្តសិទ្ធិ និងករណីយកិច្ចក្នុងការចូលរួមការពារធនធានធម្មជាតិ ។ លោក ត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់នៅពេលចុះបេសកកម្មជាមួយអ្នកសារព័ត៌មាន២រូប ចុះយកព័ត៌មាននៅជិតតំបន់ព្រៃការពារក្នុងខេត្តកោះកុង ជាទីកន្លែងដែលលោកធ្លាប់ព្យាយាមជាច្រើនដង ដើម្បីជីកកកាយសំណុំរឿងកាប់ព្រៃឈើខុសច្បាប់ ដែលមានទាក់ទងជិតស្និទ្ធនឹងមន្ត្រីយោធា ទាក់ទងនឹងការសាងសងទំនប់វារីអគ្គិសនី ។

នៅក្នុងឱកាសគម្រប់ខួប១០ឆ្នាំ នៃការបាញ់សម្លាប់នេះ យើងទាំងអស់គ្នាដែលជា សមាគម អង្គការសង្គមស៊ីវិល សកម្មជន និងសហគមន៍មូលដ្ឋាន សូមធ្វើការស្នើសុំយ៉ាងទទូចដល់រាជរដ្ឋាភិបាលជារួម និងដោយឡែកសូមជំរុញឱ្យក្រសួងពាក់ព័ន្ធរួមមាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងអាជ្ញាធរខេត្តកោះកុង ធ្វើការស៊ើបអង្កេតដែលគួរឱ្យជឿជាក់ និងហ្មត់ចត់ ដើម្បីយកអ្នកដែលពាក់ព័ន្ធទាំងអស់មកទទួលខុសត្រូវចំពោះការបាញ់សម្លាប់លោក ឈុត វុទ្ធី ។ យើងខ្ញុំ សូមធ្វើការសំណូមពរដល់ ៖

- រាជរដ្ឋាភិបាល សូមបង្កើតគណៈកម្មការឯករាជ្យ ដើម្បីធ្វើការស៊ើបអង្កេតស្វែងរកការពិតឱ្យបានឆាប់រហ័ស ប្រកបដោយតម្លាភាព និងយុត្តិធម៌ ។
- ក្រសួងយុត្តិធម៌ សូមបន្តជំរុញឱ្យស្ថាប័នអយ្យការធ្វើការស៊ើបអង្កេតដោយឯករាជ្យលើករណីនេះ ដើម្បីឈានទៅរកការកំណត់អ្នកបញ្ជា និងអ្នកពាក់ព័ន្ធ ឱ្យមកទទួលខុសត្រូវទៅតាមផ្លូវច្បាប់ ។
- ក្រសួងមហាផ្ទៃ សូមបន្តជំរុញឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបន្តដោយឯករាជ្យលើករណីនេះ ដើម្បីស្វែងរកការពិត ដោយតម្លាភាព និងយុត្តិធម៌ ។

- ក្រសួងការពារជាតិ សូមឱ្យធ្វើការស៊ើបអង្កេតដោយឯករាជ្យលើករណីឃាតកម្មនេះ ដែលរួមទាំងការប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាតពីទាហាន ឬកងរាជអាវុធហត្ថក្នុងហេតុការណ៍ដែលនាំទៅដល់ការបាញ់សម្លាប់លោក ឈុត វុទ្ធី ដែលជាសកម្មជនបរិស្ថាន និងជាជនស៊ីវិល និងការសង្ស័យថាមានការពាក់ព័ន្ធនឹងការរកស៊ីឈើដោយខុសច្បាប់ ។
- រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងបរិស្ថាន សូមមេត្តាបញ្ឈប់ការរឹតត្បិត និងធ្វើទុក្ខបុកម្នេញដោយមិនត្រឹមត្រូវមកលើសិទ្ធិសេរីភាពរបស់សហគមន៍មូលដ្ឋាន យុវជន ក៏ដូចជាអ្នកការពារធនធានធម្មជាតិនានា ក្នុងការចូលល្បាត និងការពារព្រៃឈើ និងធនធានធម្មជាតិនៅក្នុងប្រទេស ។

យើងទាំងអស់គ្នាដែលជា សមាគម អង្គការសង្គមស៊ីវិល សកម្មជន និងសហគមន៍មូលដ្ឋាន សង្ឃឹមយ៉ាងមុតមាំថារាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធខាងលើនឹងបន្តធ្វើការស៊ើបអង្កេតដោយឯករាជ្យឱ្យបានឆាប់រហ័ស និងដោយយកចិត្តទុកដាក់លើករណីបាញ់សម្លាប់សកម្មជនការពារព្រៃឈើ និងធនធានធម្មជាតិលោក ឈុត វុទ្ធី ក៏ដូចជាបញ្ឈប់ការរឹតត្បិតសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋមូលដ្ឋាន យុវជន និងអ្នកការពារធនធានធម្មជាតិ ដើម្បីឱ្យអ្នកទាំងនោះអាចចូលរួមការពារធនធានធម្មជាតិយ៉ាងសកម្មជាមួយអាជ្ញាធររដ្ឋ ៕

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

- លោក ហេង គឹមហុង ប្រធានកម្មវិធីនៃសមាគមយុវជនកម្ពុជា (CYN), ទូរស័ព្ទលេខ៖ ០៩៦ ៧៨៨ ៨៣៦៨
- លោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA), ទូរស័ព្ទលេខ៖ ០៩៣ ៦២៩ ២៩៨

*លិខិតចំហនេះគាំទ្រដោយ៖*

១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
២. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
៤. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
៥. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
៦. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)

៧. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៨. សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA)
៩. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
១០. សហគមន៍ជនជាតិដើមភាគតិចអារ៉ែង (កោះកុង)
១១. សហគមន៍ដីធ្លីចក្រី (បន្ទាយមានជ័យ)
១២. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
១៣. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
១៤. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
១៥. សហគមន៍អូរវល្លិ៍ព្រេង (បាត់ដំបង)
១៦. សហគមន៍អូរចាំស្រីត្រដក់ពង (កំពង់ធំ)
១៧. សហគមន៍មានជ័យ (ស្វាយរៀង)
១៨. សហគមន៍ពាមរស់ (កំពង់ស្ពឺ)
១៩. សហគមន៍ភ្នំក្រោម (សៀមរាប)
២០. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
២១. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)
២២. សហគមន៍ព្រៃឡង់ (កំពង់ធំ)
២៣. សហគមន៍ដីធ្លីព្រៃពាយ (កំពត)
២៤. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
២៥. សហគមន៍ព្រៃឈើទេសចរណ៍ទឹកធ្លាក់ស្រែអំពិល (កំពង់ឆ្នាំង)
២៦. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
២៧. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
២៨. សហគមន៍ដីធ្លីតានួន (កោះកុង)